គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការកណ្តាល

លេខ : ៤១ សណក.គក

សម្ងាត់បំផុត

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រិត និង វឌ្ឍនភាពសង្គម

ភ្នំពេញ , ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨

# ផែនការណែនាំ
# អំពីសភាពការណ៍ភារកិច្ចការងាររបស់
# គណៈបញ្ជាការយុទ្ធនាការបោះឆ្នោត

**************

**យោង** : ស្មារតីអង្គប្រជុំរបស់គណៈបញ្ជាការយុទ្ធនាការបោះឆ្នោត និងគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល នាថ្ងៃទី ២៣-០២-៩៨

**គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល** ណែនាំអំពីសភាពការណ៍ភារកិច្ចការងាររបស់គណៈបញ្ជាការយុទ្ធនាការបោះឆ្នោត ដូចតទៅ ៖

I — **ការវាយតំលៃសភាពការណ៍** :

- មកដល់ពេលនេះ សភាពការណ៍ទូទៅមានការវិវត្តន៍ជាវិជ្ជមាន បង្កើតបានបរិយាកាសនយោបាយអំណោយផល ដើម្បីឆ្ពោះទៅកាន់ការបោះឆ្នោតនាពេលខាងមុខ ។

ការអនុវត្តន៍នយោបាយទន់ភ្លន់ ប្រកាន់ច្បាប់ជាមូលដ្ឋានរបស់គណបក្សយើងបានទាក់ទាញប្រទេសមួយចំនួនអោយងាកមករកការពិតជាក់ស្តែង បន្ថយការប្រឆាំង និងបានលើកទឹកចិត្តដល់កំលាំងជាដៃគូអោយមានការកក់ក្តៅ មិនរត់ទៅតាមពួកជ្រុលនិយមរណប្ញទ្ធិ ហើយបានរួមជាមួយយើងបន្តនិរន្តរភាពរបស់រដ្ឋសភា និងរាជរដ្ឋាភិបាល ។ សកម្មភាពក្បត់និងអំពើល្មើសច្បាប់របស់រណប្ញទ្ធិ ត្រូវទទួលការថ្កោលទោសពីសាធារណៈមតិ ហើយនិន្នាការរួមគាំទ្រការដោះស្រាយករណីរណប្ញទ្ធិ តាមគោលការណ៍ច្បាប់ការប៉ុនប៉ងផ្តល់ការលើកលែងទោសអោយរណប្ញទ្ធិ ដោយមិនគោរពតាមនីតិវិធី ក៏ត្រូវបានប្រតិកម្មជំទាស់ជាបន្តបន្ទាប់ ។ សំណើ ៤ ចំណុចរបស់ជប៉ុន និងប្រទេសអាស៊ានទាំងបី គឺជាលក្ខខ័ណ្ឌចុងក្រោយដែលគួរពិចារណា ជាពិសេសការជំរុញ ការកាត់ទោសរណប្ញទ្ធិ ហើយបន្ទាប់មកលើកលែងទោស ដោយមានសុំទោស ដើម្បីមកចូលរួមការបោះឆ្នោត ។

ការអនុម័តច្បាប់ ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងការបង្កើតឡើងនូវគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាលទ្ធផលដំបូងយ៉ាងសំខាន់ ជំរុញអោយលេចឡើងនូវលទ្ធភាពជាក់ស្តែងនៃដំណើរការឆ្ពោះទៅកាន់ការបោះឆ្នោតឆ្នាំ ១៩៩៨ ។ គណបក្សនយោបាយភាគ

ច្រើន រួមទាំងគណបក្សដែលបានចូលរួមការបោះឆ្នោតឆ្នាំ ១៩៩៣ និងគណបក្សដែលទើបនឹងបង្កើតថ្មីមួយចំនួនទៀត កំពុងរៀបចំខ្លួនដើម្បីចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតនាពេលខាងមុខ ។ កំលាំងហ៊្វុនស៊ិនប៉ិចដែលបែកបាក់ អស់ជំនឿលើរណប្ញទ្ធិ ក៏បានបង្កើតគណបក្សថ្មីៗ ដើម្បីពង្រឹងកំលាំងចូលរួមក្នុង ការបោះឆ្នោត ។

- ទន្ទឹមនឹងចំណុចវិជ្ជមានដូចខាងលើ ក៏នៅមានផលវិបាកមួយចំនួន គឺ : កំលាំងបែកបាក់នៃពួកជ្រុលនិយម រួមជាមួយពួកឧទ្ទាមក្បាលរឹងដែលនៅសេសសល់ បន្តសកម្មភាពប្រឆាំងនឹងរាជរដ្ឋាភិបាល ប៉ុនប៉ងបង្កើតអោយមានស្ថានភាពប្រទាញប្រទង់ថ្មីខាងនយោបាយ និងយោធា សំដៅប្រែក្លាយអំពើល្មើសច្បាប់អោយទៅជាអ្វីដែលហៅថា ដំណោះស្រាយនយោបាយមួយ ប៉ុន្តែលទ្ធភាពខាងយោធារបស់គេមានកំរិត ។ ចុងក្រោយនេះពួកវាបានបង្កើនសកម្មភាពភេរវកម្ម និងសកម្មភាពនយោបាយសង្គ្រាមចិត្តសាស្ត្រ បង្កការលំបាកស្មុគស្មាញមួយចំនួនដល់រាជរដ្ឋាភិបាល ។

ពួកឧទ្ទាមកំពុងជំរុញអ្នកនយោបាយ ដែលបានរត់ទៅក្រៅប្រទេសអោយវិលត្រឡប់មកវិញ ដើម្បីធ្វើជាស្នូលនៃសកម្មភាពនយោបាយនិងគាំទ្រសកម្មភាពផ្សេងៗទៀតរបស់កំលាំងប្រឆាំង សំដៅខានកុំអោយមានការបោះឆ្នោត ។ ពួកគេកំពុងឃុបឃិតជាមួយបរទេសមួយចំនួនដើម្បីពន្យាពេលការផ្តល់ជំនួយសំរាប់ការបោះឆ្នោតធ្វើអោយដំណើរការអនុម័តច្បាប់ និង ការងារបច្ចេកទេសបោះឆ្នោតត្រូវយឺតយ៉ាវ ដើម្បីឈានទៅពន្យាពេលបោះឆ្នោតតាម ដែលគេអាចធ្វើទៅបាន ។ ពួកគេបានប្រមូលផ្តុំវាយលុកមកលើគណបក្សយើង អំពីបញ្ហាសិទ្ធិមនុស្សចោទប្រកាន់បណ្តាស្ថាប័នរដ្ឋថាមិនអព្យាក្រឹត ដើម្បីជាលេសសំរាប់ចោទថាការបោះឆ្នោត មិនមានភាពត្រឹមត្រូវយុត្តិធម៌ ហើយបដិសេធលទ្ធផលនៃការបោះឆ្នោត ក្នុងករណីដែលគណបក្សយើងទទួលបានជោគជ័យ ។

ម៉ាស៊ីនឃោសនាបរទេសមួយចំនួនបាន និងកំពុងជួយគាំទ្រកំលាំងប្រឆាំង ។

ពិនិត្យជារួម ក្នុងដំណាក់កាលឈានទៅកាន់ការបោះឆ្នោតលើកនេះ យើងមានចំណុចខ្លាំង ចំណុចខ្សោយមួយចំនួន ដូចតទៅ ÷

<u>ចំណុចខ្លាំង</u> :

- រាជរដ្ឋាភិបាលកំពុងកាន់កាប់ទាំងស្រុងនូវឧទ្ទាសម្ព័ន្ធរដ្ឋអំណាចគ្រប់ជាន់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធ តំបន់មានសង្គ្រាមតូចជាងឆ្នាំ ១៩៩៣ លទ្ធភាពបំផ្លាញរបស់ខ្មែរក្រហមមានកំរិតទាបជាងមុន ។

- ការបោះឆ្នោតចាត់ចែងដោយកម្ពុជាខ្លួនឯង ផ្ទុយពីឆ្នាំ ១៩៩៣ ដែលចាត់ចែងដោយអ៊ុនតាក់ ។ តុល្យភាពនៅក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក៏មានភាពអំណោយផលដល់ការធានាបាននូវភាពត្រឹមត្រូវនិងយុត្តិធម៌សំរាប់ការបោះឆ្នោត ។

- ជួរកំលាំងយើងគ្រប់ប្រភេទ មានបទពិសោធន៍ច្រើនជាងមុន ក្នុងការរៀបចំចូលរួមក្នុងការបោះឆ្នោតៗ ការត្រៀមរៀបចំរបស់យើងក៏ធ្វើបានច្រើនរួចមកហើយ ជាអាទិ៍ តាមរយៈសកម្មភាពរបស់ថ្នាក់ដឹកនាំ ការកសាងសមិទ្ធផលសង្គម និងសកម្មភាពក្រុមការងារចុះខេត្ត ក្រុង និងគណបក្សគ្រប់ថ្នាក់ ។

- ជួរសមាជិកគណបក្ស ត្រូវបានយកចិត្តទុកដាក់កសាងពង្រឹងពង្រីកមិនឈប់ឈរ ដែលបច្ចុប្បន្នមានចំនួនប្រមាណ ៣ លាននាក់ គួបផ្សំនឹងកំលាំងគាំទ្រផ្សេងទៀត គឺជាក្តីសង្ឃឹមដ៏ពិសិដ្ឋរបស់គណបក្សសំរាប់ឈ្នះឆ្នោត ។

- យើងបានម្ចាស់ការត្រៀមរៀបចំនូវផែនការ ដែលមានភាពជាក់ស្តែងជាងការបោះឆ្នោតឆ្នាំ ១៩៩៣ ដោយមានពេលវេលាក្នុងការអនុវត្តន៍ និងដកពិសោធន៍បានច្រើនបង្គួរ ។

- មានមូលដ្ឋានហិរញ្ញវត្ថុសំរាប់អនុវត្តនូវកិច្ចការជាគន្លឹះសំខាន់ៗនៃការងារ ។

- គូប្រជែងសំខាន់របស់យើងកំពុងត្រូវបែកបាក់ចុះខ្សោយ ជាប់ជុំទាំងខាងនយោបាយ និងផ្លូវច្បាប់ ។

<u>ចំណុចខ្សោយ</u> :

- មជ្ឈដ្ឋានបរទេសមួយចំនួនដែលប្រឆាំងយើង នៅបន្តជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងកម្ពុជា ជួយគាំទ្រកំលាំងប្រឆាំងក្នុងការអនុវត្តន៍ឧបាយកលពិសពុល ប៉ុនប៉ងផ្តួលរំលំយើងតាមគ្រប់រូបភាព ពិសេសតាមរយៈការបោះឆ្នោត ។

- កំលាំងគូប្រជែងដែលបែកបាក់ ពិតមែនត្រូវចុះខ្សោយ និងជួបការលំបាក ប៉ុន្តែពួកគេនៅមានបង្អែកពីខាងក្រោយ រៀបចំសេណារីយ៉ូតស៊ូជាមួយយើងតាមរូបភាពសហការផង ប្រឆាំងផង ។ ហេតុនេះការបោះឆ្នោតលើកនេះ ជាការបោះឆ្នោតរវាងយើងនឹងពួកបរទេស និងកំលាំងមិនចេញមុខដែលនៅពីក្រោយឆាក ប្រហាក់ប្រហែលឆ្នាំ ១៩៩៣ ដែរ ។

- ស្ថានភាពសេដ្ឋកិច្ច ហិរញ្ញវត្ថុ យើងកំពុងមានការលំបាក បណ្តាលមកពីឥទ្ធិពលរួមនៃវិបត្តិសេដ្ឋកិច្ចក្នុងតំបន់ផង និងកត្តាអត្តនោម័តិផង ។ ពួកវិច្ចេទកម្មសេដ្ឋកិច្ចអាចប្រើប្រាស់បញ្ហានេះ ដែលបាននិងកំពុងជះឥទ្ធិពលដល់ជីវភាពរបស់មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ និងប្រជាជន ។

- បាតុភាពអសកម្មរបស់មន្ត្រីរាជការ កងកំលាំងប្រដាប់អាវុធ ជាសមាជិកគណបក្ស ដែលធ្វើអោយប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាជន ក៏កំពុងជះឥទ្ធិពលមិនល្អ បន្ថយសន្លឹកឆ្នោតរបស់គណបក្ស ។

- បរិមាណសមាជិកគណបក្សនៅតំបន់មួយចំនួនមិនទាន់ប្រាកដប្រជាទេ កន្លែងខ្លះនៅរាយការណ៍យកស្នាដៃ ហើយរបៀបចុះមូលដ្ឋានរបស់មន្ត្រីយើងចាំបាច់ត្រូវកែលំអថែមទៀត ដើម្បីអោយបានទៅដល់ផ្ទាល់ជាមួយប្រជាជន និងសមាជិកគណបក្សពិតប្រាកដ ។

## II — ទិសដៅការងារសំខាន់ៗឆ្ពោះទៅកាន់ការបោះឆ្នោត :

### ១ — ទិសដៅ :

ត្រូវប្រមូលផ្តុំតំរង់ទិសគ្រប់វិស័យការងារលើបញ្ហាគន្លឹះ ៣ នៃការបោះឆ្នោតអោយមានដំណើរការព្រមៗគ្នា ÷

គន្លឹះទី ១ :

យុទ្ធសាស្ត្រជាគន្លឹះរបស់គណបក្សយើងគឺត្រូវប្រមូលសមាជិកគណបក្ស ដែលបច្ចុប្បន្នមានជាង ៣ លាននាក់បោះឆ្នោតជូនគណបក្ស ធានាអោយបាននូវរូបមន្ត ១ + ៗ ត្រូវខិតខំអនុវត្តអោយបាននូវសំណូមពរ ៣ នៃការងារកសាងពង្រឹងសមាជិកគណបក្ស គឺ ៖ សមាជិកគណបក្សមានការប្តេជ្ញាចិត្តខ្លួនឯង និងចេះចលនាសាច់ញាតិ និងអ្នកជិតខាងអោយសំរេចចិត្តបោះឆ្នោតជូនគណបក្ស និងហ៊ានប្រឆាំងនឹងការឃោសនារបស់គណបក្សដទៃដែលធ្វើប៉ះពាល់ផលប្រយោជន៍របស់គណបក្សយើង សមាជិកគណបក្សបានចុះឈ្មោះបោះឆ្នោត-សមាជិកគណបក្សបានទៅបោះឆ្នោត និងចេះបោះឆ្នោតជូនគណបក្ស ។ ព្រមជាមួយនេះ ត្រូវជំរុញការងារឃោសនាដណ្តើមសមានចិត្តប្រជាជន ដោយឈរលើគោលការណ៍ពង្រីកស្នាដៃ គុណបំណាច់របស់គណបក្ស ជាពិសេសការសង្គ្រោះប្រទេសជាតិ និងប្រជាជន ពីរបបប្រល័យពូជសាសន៍ ការកសាងសមិទ្ធិផលច្រើនគួបផ្សំនឹងការខិតខំដោះស្រាយបញ្ហាអសកម្មដែលធ្វើអោយប្រជាជនថ្នាំងថ្នាក់ ។

គន្លឹះទី ២ :

ត្រូវខិតខំក្តាប់អោយបាននូវការងារបច្ចេកទេសបោះឆ្នោត ដើម្បី ÷

- គណៈកម្មាធិការជាតិ និងខ្សែរយៈរៀបចំការបោះឆ្នោត គ្រប់ជាន់ថ្នាក់ ត្រូវអព្យាក្រឹត មិនលំអៀង ធានាភាពត្រឹមត្រូវ យុត្តិធម៌ និងធ្វើសកម្មភាពទៅតាមការកំណត់នៃច្បាប់ ។
- ទប់ស្កាត់បានការប៉ុនប៉ងលួចបន្លំតាមគ្រប់រូបភាពរបស់ភាគីប្រឆាំង និងទប់ស្កាត់ការចោទប្រកាន់ដោយអយុត្តិធម៌មកលើគណបក្សយើង ។

គន្លឹះទី ៣ :

ត្រូវមានថវិកាដើម្បីចាត់ចែងការងារអោយបានទាន់ពេលវេលា ផ្តល់អាទិភាពលើការងារយុទ្ធសាស្ត្រគន្លឹះ គឺការកសាងពង្រឹងសមាជិកគណបក្ស ការងារឃោសនា និងការអប់រំបណ្តុះបណ្តាលសមាជិកគណបក្ស និងអ្នកធ្វើការរៀបចំការបោះឆ្នោតគ្រប់ប្រភេទរបស់យើង ។

### ២ — ការងារសំខាន់ៗដែលត្រូវយកចិត្តទុកដាក់អនុវត្តបន្ត :

ដើម្បីសំរេចបានការងារជាយុទ្ធសាស្ត្រដូចខាងលើនេះ ចាំបាច់ត្រូវយកចិត្តទុកដាក់អនុវត្តអោយបានល្អនូវការងារសំខាន់ៗ ៦ គឺ ៖

<u>ទីមួយ</u> : បន្តជំរុញការងារបោះឆ្នោតអោយប្រព្រឹត្តទៅបានតាមការកំណត់នៅថ្ងៃទី ២៦ កក្កដា ១៩៩៨ៗ

- គណៈកម្មាធិការគណបក្សខេត្ត ក្រុង ក្រសួង ស្ថាប័នទាំងអស់ ត្រូវទទួលខុសត្រូវដឹកនាំទាំងស្រុងការងារត្រៀមរៀបចំ និងប្រតិបត្តិការនៃការបោះឆ្នោតនេះ អោយទទួលបានលទ្ធផលល្អ ហើយថែមទាំងការពារបានលទ្ធផលនេះនៅក្រោយការបោះឆ្នោត ។

-ត្រូវបន្តពង្រឹងតួនាទីជាស្នូលរបស់យើងក្នុងរដ្ឋសភា និងរាជរដ្ឋាភិបាល ដើម្បីជំរុញអោយការបោះឆ្នោតប្រព្រឹត្តទៅបានតាមការកំណត់ ។

- ក្រុមសភា ត្រូវបន្តជំរុញការអនុម័តច្បាប់ទាំង ២ : ច្បាប់ស្តីពីក្រុមប្រឹក្សាធម្មនុញ្ញ ច្បាប់ស្តីពីគណនេយ្យពិសេស និងច្បាប់ផ្សេងៗ ដើម្បីបំពេញសំណូមពរខាងច្បាប់សំរាប់ការបោះឆ្នោតអោយទាន់ពេលវេលា ។

- ជំរុញដំណើរការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អោយបានឆាប់រហ័ស ទាន់ពេលវេលាដែលច្បាប់កំណត់ ។

- ទប់ស្កាត់គេលល្បិចប្រើប្រាស់ជំនួយ ពន្យាការផ្តល់ជំនួយ ដែលធ្វើអោយប៉ះពាល់ដល់កាលបរិច្ឆេទនៃការបោះឆ្នោត ។

- ជំរុញរាជរដ្ឋាភិបាលធានានូវការផ្តល់ថវិកាមួយចំនួនដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងត្រៀមបំរុងក្នុងករណីដែល ជំនួយផ្តល់មិនទាន់ ហើយត្រូវចំណាយទាំងស្រុងសំរាប់ការបោះឆ្នោត ។

ទីពីរ : បន្តខិតខំរក្សាប្រក្រតីភាពនៃសន្តិសុខជាតិលើគ្រប់វិស័យ សំដៅធានាដល់ការបង្កបរិយាកាសនយោបាយសំរាប់ការបោះឆ្នោត ដែលអាចទទួលយកបានជាទូទៅ ។

- បន្តទប់ស្កាត់រាល់សកម្មភាពយោធារបស់ពួកខ្មាំងគ្រប់ប្រភេទ មិនអោយពួកវាពង្រីងពង្រីកកំលាំង និងបង្កើតតំបន់កាន់កាប់នៅតាមព្រៃផ្សៃបាន ដោយតួបផ្សំការគាបសង្កត់ដោយកំលាំងយោធា ការចលនាអូសទាញអោយវិលត្រឡប់មករួមជាមួយរាជរដ្ឋាភិបាលវិញ និងទប់ស្កាត់សកម្មភាពអូសទាញកំលាំងទៅព្រៃផ្សៃ ។

- ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សង្គម យកចិត្តទុកដាក់ទប់ស្កាត់សកម្មភាពភេរវកម្ម វិទ្ធង្សនកម្មគ្រប់ប្រភេទ និងការបំផុសចលនាបាតុកម្មប្រឆាំងរាជរដ្ឋាភិបាល បង្កអស្ថិរភាពក្នុងសង្គម ។

- ខិតខំរក្សាស្ថិរភាពខាងសេដ្ឋកិច្ច ទប់ស្កាត់អតិផរណាអោយស្ថិតក្នុងកំរិតដែលអាចទទួលយកបាន កាត់បន្ថយជាអតិបរមានូវការជះឥទ្ធិពលពីវិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុក្នុងតំបន់ ។

- ខិតខំដោះស្រាយបញ្ហាជីវភាព ជាពិសេសដោះស្រាយបៀវត្សដល់មន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធអោយបានទាន់ពេលវេលា និងជួយសង្គ្រោះប្រជាជនដែលរងគ្រោះផ្សេងៗ ខិតខំរក្សាស្ថិរភាពជីវភាពរបស់ប្រជាជន ។

__ទី បី__ : បន្តខិតខំបង្កើនប្រជាប្រិយភាពរបស់គណបក្ស ពុះពារបំបាត់អោយបានជាអតិបរមានូវចំណុចខ្សោយរបស់យើង ពិសេសអំពើខុសឆ្គងរបស់មន្ត្រីយើងដែលជាប្រភពគន្លឹះនៃការថ្នាំងថ្នាក់របស់មហាជនប្រជាជន នាបច្ចុប្បន្ននេះដើម្បីបន្សាបឥទ្ធិពលនៃការឃោសនារបស់គណបក្សប្រកួតប្រជែង ដែលឆ្លៀតយកចំណុចខ្សោយរបស់យើងទៅធ្វើអាជីវកម្មសំរាប់ផលប្រយោជន៍នៃគណបក្សគេ ។

- បន្តឃោសនាអប់រំពង្រឹងផ្ទៃក្នុង និងធ្វើអោយមហាជន ប្រជាជនឃើញគុណបំណាច់ដ៏ធំធេងរបស់គណបក្សយើង ក្នុងការសង្គ្រោះប្រទេសជាតិ និងប្រជាជនពីរបបប្រល័យពូជសាសន៍ និងទប់ស្កាត់ការប៉ុនប៉ងវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍ ការធ្វើអោយប្រទេសជាតិរស់ឡើងវិញ ការស្វែងរកសន្តិភាព និងការបង្រួបបង្រួមជាតិ ការទប់ស្កាត់សកម្មភាពរបស់កំលាំងអនាធិបតេយ្យជ្រុលនិយម ឃុបឃិតជាមួយឧទ្ទាមខ្មែរក្រហម ការបួរផ្តាច់ការពាររដ្ឋធម្មនុញ្ញ រក្សាស្ថិរភាពនយោបាយសង្គម និងសមិទ្ធផលដ៏ធំធេងរបស់គណបក្សក្នុងការស្តារនិងអភិវឌ្ឍប្រទេស ។ ជារួមត្រូវធ្វើអោយឃើញថាគណបក្សយើងជាគណបក្សតំណាងអោយផលប្រយោជន៍ជាតិ និងផលប្រយោជន៍ប្រជាជនទូទៅ ។

- បន្តជំរុញសកម្មភាពចុះមូលដ្ឋាន កែលំអរបៀបចុះមូលដ្ឋាន ផ្សារភ្ជាប់ជាមួយមហាជន ប្រជាជន ជួយដោះស្រាយការលំបាក និងលើកស្ទួយជីវភាពប្រជាជន ។ ត្រូវយកចិត្តទុកដាក់ដោះស្រាយសំណូមពរ ជួយបង្កលក្ខណៈងាយស្រួលដល់ប្រជាជន តាមសមត្ថកិច្ច និងតួនាទីរបស់ខ្លួន ហើយចៀសវាងដាច់ខាតរាល់អំពើដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាជន ។ ទន្ទឹមនេះ មន្ត្រីដឹកនាំយើងត្រូវយកចិត្តទុកដាក់អប់រំទប់ស្កាត់ មិនបណ្តែតបណ្តោយអោយកូនក្មួយ សាច់ញាតិប្រព្រឹត្តអំពើផ្តេសផ្តាស ប៉ះពាល់ដល់ប្រជាជន និងសណ្តាប់ធ្នាប់សង្គម ។ បន្តអនុវត្តល្អនូវបទបញ្ជា ៨ ចំណុចរបស់រាជរដ្ឋាភិបាល ។

- មានវិធានការដោះស្រាយ ផ្លាស់ប្តូរចំពោះមន្ត្រីដែលពិនិត្យឃើញថាមានកំហុសឆ្គងធ្វើអោយប៉ះពាល់ដល់ឥទ្ធិពលរបស់គណបក្ស និងថ្នាក់ដឹកនាំ ហើយមិនអំណោយផលដល់ការឃោសនាបោះឆ្នោតរបស់គណបក្សតាមកន្លែងនីមួយៗ ។

__ទី បួន__ : ប្រមូលផ្តុំកំលាំងសរុប មធ្យោបាយសរុប វិធានការសរុបរបស់គណបក្សចូលរួមបំរើអោយការបោះឆ្នោត ដោយត្រូវកំណត់ច្បាស់កត្តាគន្លឹះសំខាន់បំផុតរបស់គណបក្ស ដើម្បីដណ្តើមជោគជ័យក្នុងការបោះឆ្នោត គឺការគ្រប់គ្រងសមាជិក និងចលនាសមាជិកគណបក្សគ្រប់រូបបោះឆ្នោតអោយគណបក្ស ។

- ត្រូវធ្វើអោយមន្ត្រីដឹកនាំរបស់គណបក្សយើងនៅគ្រប់ថ្នាក់ គ្រប់ផ្នែក យល់ច្បាស់អំពីជោគវាសនា និងអាជីពរបស់គេ ទាក់ទងនឹងលទ្ធផលនៃការបោះឆ្នោត « ទាំងអស់គ្នាត្រូវខិតខំដើម្បីឈ្នះឆ្នោត » ។

- ត្រួតពិនិត្យជំរុញការចាត់តាំងក្បាលម៉ាស៊ីនដឹកនាំការងារបោះឆ្នោត ចាប់ពីថ្នាក់កណ្តាលរហូតដល់មូលដ្ឋាន និងបណ្តាផ្នែកការងារចំណុះថ្នាក់នីមួយៗអោយបានរួចរាល់ ហើយចាប់ផ្តើមដំណើរការការងារភ្លាម ។

- ក្រុមការងារចុះជួយដល់មូលដ្ឋាន ត្រូវបន្តពង្រឹងខ្សែរយៈគណបក្សអោយបានច្បាស់លាស់ រឹងមាំពិតប្រាកដ ជាពិសេសខ្សែរយៈគណបក្សនៅមូលដ្ឋាន ឃុំ ភូមិ ក្រុមបក្ស និងដំណើរការចុះបញ្ជីសមាជិកក្រុមបក្សនីមួយៗឡើងវិញ តាមតំរូវការនៃឯកភាព ដើម្បីគ្រប់គ្រងពង្រឹងសមាជិកគណបក្ស ធានាអោយសមាជិកគណបក្សគ្រប់រូបបានទៅចុះឈ្មោះបោះឆ្នោត ទៅបោះឆ្នោត និងចេះបោះឆ្នោតអោយគណបក្ស ។

ជាវិធានការអនុវត្តការងារសំខាន់ទី ៣ និងទី ៤ ចាំបាច់ត្រូវតែចាត់តាំងការប្រជុំជីវភាពឡើងវិញនៅគ្រប់សាខា អនុសាខា ក្រុមបក្ស តាំងពីថ្នាក់កណ្តាល រហូតដល់មូលដ្ឋាន ដើម្បីត្រួតពិនិត្យសមាជិក និងអង្គការចាត់តាំងគណបក្ស ត្រួតពិនិត្យអ្វីដែលធ្វើបាន និងអ្វីដែលធ្វើមិនបាន ឬធ្វើខុសឆ្គង ព្រមទាំងទិសដៅ និងការងារត្រូវអនុវត្តបន្ត ។ វគ្គប្រជុំជីវភាពនយោបាយទូទាំងប្រទេសនេះ ចាំបាច់ត្រូវធ្វើអោយបានយ៉ាងហោចណាស់ ១ ដង នៅក្រោយពេលសន្និបាតនៃគណៈកម្មាធិការកណ្តាលលើកទី ២៤ បើកទូលាយ ១ ដងនៅមុនពេលបើកការចុះឈ្មោះបោះឆ្នោត ១ ដងមុនពេលបើកយុទ្ធនាការឃោសនាបោះឆ្នោត ១ ដងនៅពាក់កណ្តាលយុទ្ធនាការ និង ១ ដងនៅមុនថ្ងៃបោះឆ្នោត ។

ទី_ប្រាំ : រក្សា និងពង្រឹងសម្ព័ន្ធភាពជាមួយគណបក្សនយោបាយនានា តាមគោលការណ៍រួមនៃគណបក្សសម្ព័ន្ធភាពដែលបានប្រកាសរួចមកហើយ ។ យកចិត្តទុកដាក់ពង្រីកសម្ព័ន្ធភាពជាមួយគណបក្សផ្សេងទៀត និងទាក់ទាញគណបក្សនយោបាយអោយបានច្រើនចូលរួមក្នុងការបោះឆ្នោត ដើម្បីពង្រឹងឧត្តមភាពលើកំលាំងប្រឆាំងនឹងការបោះឆ្នោត និងការធ្វើពហិការចំពោះការបោះឆ្នោត ។ ប៉ុន្តែទន្ទឹមនេះ ត្រូវយកចិត្តទុកដាក់ចំពោះគណបក្សខ្លះក្នុងសម្ព័ន្ធភាព ដែលវៀតយកចំណេញពីគណបក្សយើង ។

ទីប្រាំមួយ : ពង្រឹងការងារទំនាក់ទំនងបរទេស និងការងារចលនាទាក់ទាញអង្គការក្រៅរដ្ឋាភិបាល ទាំងក្នុងប្រទេស និងអន្តរជាតិ ។

- បន្តទាក់ទាញបណ្តាប្រទេសអោយគាំទ្រ និងផ្តល់ជំនួយសំរាប់ការបោះឆ្នោតឆ្នាំ ១៩៩៨ នៅកម្ពុជា ។ ត្រូវចេះបន្ទន់ឥរិយាបថទាក់ទាញមជ្ឈដ្ឋានអន្តរជាតិមួយចំនួនដែលប្រឆាំងយើង ធ្វើអោយគេយល់យើង និងបន្ថយភាពតានតឹងប្រឈមមុខជាមួយយើង ។

- ត្រូវឃើញច្បាស់អំពីតួនាទីដ៏សំខាន់របស់អង្គការក្រៅរដ្ឋាភិបាល ក្នុងការបញ្ជាក់ពីភាពសេរី ត្រឹមត្រូវ យុត្តិធម៌នៃការបោះឆ្នោត ក្រោយពេលប្រកាសលទ្ធផលនៃការបោះឆ្នោត ដែលនឹងជះឥទ្ធិពលខ្លាំងណាស់ដល់សាធារណមតិជាតិ និងអន្តរជាតិ ។ បន្តទាក់ទាញបញ្ចុះបញ្ចូលអង្គការក្រៅរដ្ឋាភិបាលនានា ទាំងក្នុងប្រទេស និងអន្តរជាតិអោយជួយគាំទ្រយើង និងចូលរួមក្នុងសកម្មភាពនានាជាផលប្រយោជន៍សំរាប់គណបក្សយើងក្នុងយុទ្ធនាការបោះឆ្នោត ។

៣ — **ភារកិច្ចការងាររបស់គណៈបញ្ជាការយុទ្ធនាការបោះឆ្នោត** :

គណៈបញ្ជាការយុទ្ធនាការបោះឆ្នោតមានភារកិច្ច ធ្វើជាសេនាធិការជូនគណៈអចិន្ត្រៃយ៍ និងគណៈកម្មការបោះឆ្នោតនៃគណៈកម្មាធិការកណ្តាល ដើម្បីដឹកនាំចាត់ចែងអនុវត្តរាល់ជំហាននៃការងារបោះឆ្នោតអោយបានជោគជ័យ តាមសេចក្តីសំរេចចិត្ត ស្តីពីផែនការឆ្ពោះទៅកាន់ការបោះឆ្នោតឆ្នាំ ១៩៩៨ ដែលសន្និបាតគណៈកម្មាធិការកណ្តាលលើកទី ២៣ បានដាក់ចេញ ។

ក្រុមប្រចាំការរបស់គណៈបញ្ជាការ មានភារកិច្ចចាត់ចែងដោះស្រាយការងារប្រចាំថ្ងៃ ហើយបូកសរុបរាយការណ៍ជូនគណៈបញ្ជាការយុទ្ធនាការបោះឆ្នោត គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងត្រូវរៀបចំកម្មវិធី ខ្លឹមសារសំរាប់ប្រជុំគណៈបញ្ជាការយុទ្ធនាការបោះឆ្នោត ដើម្បីពិនិត្យសំរេចដោះស្រាយនូវបញ្ហាសំខាន់ៗ ។

ដើម្បីសំរេចភារកិច្ចរួមដូចខាងលើ គណៈបញ្ជាការយុទ្ធនាការបោះឆ្នោត កំណត់ភារកិច្ចជាក់ស្តែងរបស់បណ្តាគណៈកម្មការជំនួយការ ដូចខាងក្រោម ÷

* **គណៈកម្មការឃោសនា សោតទស្សន៍ បោះពុម្ពផ្សាយ Internet** :

ត្រូវចាត់តាំងអនុវត្តអោយបានល្អនូវសេចក្តីណែនាំ អំពីទិសដៅសំខាន់ៗមួយចំនួននៃការងារឃោសនាឆ្ពោះទៅកាន់ការបោះឆ្នោត លេខ ៣៨ សណ.គក ចុះថ្ងៃទី ៤-២-៩៨ របស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ។ ក្នុងនោះរួមមានការងារសំខាន់ៗ គឺ ៖

- ការងារកសាងឯកសារនយោបាយ
- ការងារសោតទស្សន៍
- ការងារសារពត៌មាន និងប្រតិកម្មរហ័ស
- ការងាររៀបចំមិទ្ទីង សម្ពោធសមិទ្ធិនានារបស់គណបក្ស និងកាប្រជុំប្រជាជន
- ការងារឃោសនាចល័ត
- ការងារស្រាវជ្រាវ និងស្ទង់មតិ
- ការងារបោះពុម្ពផ្សាយ ផលិត សំភារៈឃោសនា និងរៀបចំពិពណ៌ផ្សារណាត់

- ការផ្សាយពត៌មានទៅក្រៅប្រទេសតាម Internet

- ការងារអប់រំបណ្តុះបណ្តាល

* **គណៈកម្មការចលនាមហាជន និងទំនាក់ទំនងជាមួយ NGO :**

- ពង្រឹងអង្គការសង្គមរបស់គណបក្ស ដឹកនាំសកម្មភាពរបស់អង្គការទាំងនោះចូលរួមចំណែកអនុវត្ត គោលនយោបាយរបស់គណបក្ស និងចលនាមហាជន ប្រជាជនគ្រប់ស្រទាប់បោះឆ្នោតអោយគណបក្ស ។

- គ្រប់គ្រង និងធ្វើសកម្មភាពបញ្ចុះបញ្ចូលអង្គការក្រៅរដ្ឋាភិបាលទាំងក្នុង និងក្រៅប្រទេស អោយគាំទ្រ និងចូលរួមចំណែកអនុវត្តនយោបាយរបស់គណបក្ស សំរាប់ការអភិវឌ្ឍន៍ជនបទ ការងារសង្គមកិច្ច និងកិច្ចការផ្សេងៗទៀត ដែលមានប្រយោជន៍ដល់សង្គមជាតិ និងដល់គណបក្ស ។

- ផ្សព្វផ្សាយនូវមាគ៌ា គោលនយោបាយរបស់គណបក្សអោយបានជ្រួតជ្រាបទៅផ្ទៃក្នុងរបស់អង្គការក្រៅរដ្ឋាភិបាល ។

* **គណៈកម្មការច្បាប់ និងនីតិវិធីបោះឆ្នោត :**

- ស្រាវជ្រាវ និងបន្តជំរុញការអនុមតិច្បាប់ និងបទបញ្ញាផ្សេងៗសំរាប់ធានាដល់ការបោះឆ្នោត ដោយរក្សាដំបារការពារអធិបតេយ្យជាតិ ធានាអព្យាក្រឹតភាពនៃស្ថាប័នរដ្ឋ និងភាពសេរី ត្រឹមត្រូវ យុត្តិធម៌សំរាប់ការបោះឆ្នោត ដែលគណបក្សនយោបាយភាគច្រើនអាចទទួលយកបាន ។

ស្រាវជ្រាវ ចងក្រងឯកសារពាក់ព័ន្ធនឹងច្បាប់ និងសេចក្តីកំណត់ផ្សេងៗពាក់ព័ន្ធដល់ការបោះឆ្នោត សំរាប់បំពាក់បំប៉នដល់មន្ត្រីគណបក្សយើងដែលត្រូវបានចាត់តាំងអោយទៅបំរើការងារបោះឆ្នោតនៅគ្រប់ថ្នាក់ និងសំរាប់ប្រើប្រាស់ក្នុងការងារបោះឆ្នោត ។

- សហការរៀបចំឯកសារសំរាប់ប្តឹងចំពោះគណបក្ស ឬបុគ្គលណាដែលមានការរំលោភមកលើគណបក្សយើង ។

- ចាត់តាំងក្រុមមេធាវីរបស់គណបក្ស ។

- ទទួលពាក្យបណ្តឹង និងស្រាវជ្រាវសហការបកស្រាយចំពោះករណីដែលមានការចោទប្រកាន់មកលើគណបក្សយើង ។

* **គណៈកម្មការកសាងពង្រឹងកំលាំងសមាជិកគណបក្ស :**

- ដឹកនាំ ត្រួតពិនិត្យ ការចាត់តាំងកសាងពង្រឹង និងគ្រប់គ្រងសមាជិកគណបក្ស ការចុះបញ្ជីសមាជិកក្រុមបក្ស ។

- គ្រប់គ្រងមន្ត្រីរបស់គណបក្ស  ពិនិត្យរួមយោបល់អំពីការផ្លាស់ប្តូរមន្ត្រី និងការរៀបចំពង្រឹងរចនាសម្ព័ន្ធរបស់គណបក្ស ។

- ធ្វើផែនការណែនាំ អំពីការជ្រើសរើស និងចាត់តាំងបំប៉នមន្ត្រីរបស់គណបក្ស ធ្វើជាអ្នកសង្កេតការណ៍ និងភ្នាក់ងារគណបក្សសំរាប់ចូលរួមបំរើការបោះឆ្នោតនៅគ្រប់ថ្នាក់  និងត្រៀមសមាសភាពសំរាប់គណៈកម្មាធិការជាតិ  រៀបចំការបោះឆ្នោត  ជ្រើសរើសចូលបំរើការងារនៅក្នុងគណៈកម្មការបោះឆ្នោត គ្រប់ថ្នាក់  អគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានបោះឆ្នោត ។

* **គណៈកម្មការសរុប រដ្ឋបាល បញ្ជូនសារ** :

- រួមជាមួយខុទ្ទកាល័យគណៈកម្មាធិការកណ្តាល  ដើម្បីធានាការប្រមូលពត៌មាន  ការបញ្ជូនឯកសារ ការគ្រប់គ្រងទូរលេខ និងវិទ្យុទាក់ទងពីថ្នាក់កណ្តាលដល់ខេត្ត ក្រុង  ការធ្វើលិខិតអញ្ជើញប្រជុំការងារបោះឆ្នោត។

- ធ្វើរបាយការណ៍បូកសរុបការងាររបស់គ្រប់គណៈកម្មការជំនួយការ  និងសកម្មភាពការងារបោះឆ្នោត ដើម្បីរាយការណ៍ជូនគណៈបញ្ជាការយុទ្ធនាការបោះឆ្នោត និងគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ។

- រៀបចំកម្មវិធី  និងខ្លឹមសារសំរាប់ប្រជុំក្រុមប្រចាំការ  និងគណៈបញ្ជាការយុទ្ធនាការបោះឆ្នោត  និងធ្វើកំណត់ហេតុរាយការណ៍ជូនគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ។

- ស្រាវជ្រាវរៀបចំពង្រឹងប្រព័ន្ធទាក់ទងពត៌មានលើមូលដ្ឋានមធ្យោបាយដែលមានស្រាប់ ពីថ្នាក់កណ្តាលរហូតដល់ស្រុក ខណ្ឌ ។

* **គណៈកម្មការការងារដឹកជញ្ជូន** :

- ក្តាប់ស្ថិតិប្រជាជនដែលត្រូវទៅបោះឆ្នោត  កន្លែងបោះឆ្នោត និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ។

- ធ្វើផែនការធានាការដឹកជញ្ជូនប្រជាជន និងសមាជិកគាំទ្រគណបក្សដែលរស់នៅតំបន់ដាច់ស្រយាលទៅកាន់ការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត ។

- ធ្វើផែនការធានាមធ្យោបាយដឹកជញ្ជូនមន្ត្រី និងភ្នាក់ងារគណបក្សយើងទៅតាមក្បួនដំណើរដឹកហិបឆ្នោត និងឯកសារទៅកាន់ខេត្ត ក្រុងក្រោយពេលចប់ការរាប់សន្លឹកឆ្នោត ។

* **គណៈកម្មការទំនាក់ទំនងបរទេស** :

- បន្តខិតខំពង្រឹងពង្រីកទំនាក់ទំនងជាមួយបណ្តាប្រទេសជាមិត្ត  ដើម្បីទាក់ទាញការគាំទ្រចំពោះគណបក្សយើង សំរាប់គ្រប់យថាហេតុក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោត ។

- ទំនាក់ទំនងសហការអោយបានល្អជាមួយអ្នកសង្កេតការណ៍បរទេស  ដើម្បីទាក់ទាញការគាំទ្ររបស់គេចំពោះគណបក្សយើង ។

- ធ្វើឯកសារផ្សេងៗដែលចាំបាច់បំរើអោយសំណូមពរនៃការងារតស៊ូការទូតក្នុងពេលបោះឆ្នោត ។

* **គណៈកម្មការសម្ព័ន្ធភាព** :

- ចលនាគ្រប់គណបក្សសម្ព័ន្ធភាពគាំទ្រ និងចូលរួមការបោះឆ្នោត ថ្ងៃ ២៦-៧-៩៨ តាមការកំណត់នៃច្បាប់បោះឆ្នោត ។

- ពិភាក្សាជាមួយគណបក្សសម្ព័ន្ធភាពនីមួយៗដើម្បីកំណត់ទិសដៅរួមសំរាប់ការឃោសនាបោះឆ្នោត និងកិច្ចសហប្រតិបត្តិការគ្នាក្នុងដំណាក់កាលមុន ក្នុង និងក្រោយពេលបោះឆ្នោត ។

* **គណៈកម្មការហិរញ្ញវត្ថុបោះឆ្នោត** :

- កសាងគំរោងផែនការហិរញ្ញវត្ថុសំរាប់ការបោះឆ្នោត តាមជំហាននីមួយៗ ។

- ខិតខំស្វែងរកប្រភពចំណូលខ្ពស់បំផុតសំរាប់បំរើអោយការបោះឆ្នោត អំពាវនាវរកការគាំទ្រខាងហិរញ្ញវត្ថុពីគ្រប់មជ្ឈដ្ឋាន ។

- រៀបចំបញ្ជីចំណូលចំណាយហិរញ្ញវត្ថុគណបក្សមានសក្ខីបត្រស្របច្បាប់គ្រប់គ្រាន់ ត្រៀមសំរាប់ការត្រួតពិនិត្យរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

* **វិធីការពារសន្តិសុខសំរាប់ការបោះឆ្នោត** :

នេះជាបន្ទុកទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានផែនការរៀបចំកំលាំង ដើម្បីរក្សាការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងរបៀបរៀបរយសំរាប់បំរើដល់ការបោះឆ្នោត ។ ត្រូវមានផែនការការពារសន្តិសុខដល់ស្នាក់ការគណបក្ស មន្ត្រីភ្នាក់ងារគណបក្ស និងឯកសាររបស់គណបក្សអោយបានល្អ ។ ទន្ទឹមនេះ ក៏ត្រូវមានការណែនាំអោយកម្មាភិបាល យុទ្ធជន ជាសមាជិកគណបក្សបោះឆ្នោតជូនគណបក្ស ។

III — **វិធីរបៀបធ្វើការ** :

- កន្លែងធ្វើការរបស់គណៈបញ្ជាការយុទ្ធនាការបោះឆ្នោត ក្រុមប្រចាំការ និងបណ្តាគណៈកម្មការជំនួយការ នៅខុទ្ទកាល័យគណៈកម្មាធិការកណ្តាល ។

- គណៈបញ្ជាការយុទ្ធនាការបោះឆ្នោត ប្រជុំ ១ ខែម្តង ហើយនៅពេលខាងមុខដែលជិតឈានដល់ការបោះឆ្នោត ត្រូវប្រជុំ ១ ខែ ២ ដង ដើម្បីពិនិត្យសំរេចបញ្ហាសំខាន់ៗ នៃការងារបោះឆ្នោត ។

- ក្រុមប្រចាំការរបស់គណៈបញ្ជាការយុទ្ធនាការបោះឆ្នោតប្រជុំ ១ សប្តាហ៍ម្តង នៅរាល់ល្ងាចថ្ងៃអង្គារ និងចាត់ចែងដោះស្រាយការងារប្រចាំថ្ងៃ ។

- គណៈកម្មការសរុប រដ្ឋបាល បញ្ជូនសារ ជាអ្នកសំរបសំរួលរៀបចំកម្មវិធីការងាររបស់ក្រុមប្រចាំការ និងគណៈបញ្ជាការយុទ្ធនាការបោះឆ្នោត និងរួមសហការជាមួយខុទ្ទកាល័យគណៈកម្មាធិការកណ្តាល ដើម្បីទំនាក់ទំនងរាយការណ៍សុំយោបល់គណៈប្រចាំការ និងគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ។

- បណ្តាគណៈកម្មការជំនួយការត្រូវប្រញាប់រួសរាន់កោះប្រជុំគណៈកម្មការជំនាញរបស់ខ្លួនភ្លាម ដើម្បីកំណត់បែងចែកភារកិច្ចការងារជាក់ស្តែងក្នុងគណៈកម្មការ ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវទទួលខុសត្រូវជំនួសប្រធាន ដើម្បីរៀបចំកម្មវិធី និងដឹកនាំការប្រជុំលើកដំបូងរបស់គណៈកម្មការ ។

ត្រូវកសាងផែនការ ទិសដៅសំខាន់ៗនៃការងារជំនាញរបស់ខ្លួន និងផ្តើមគំនិតជូនក្រុមប្រចាំការ និងគណៈបញ្ជាការយុទ្ធនាការបោះឆ្នោត លើភារកិច្ចការងារជំនាញដែលបានកំណត់ ។ គ្រប់របាយការណ៍របស់គណៈកម្មការជំនួយការត្រូវផ្ញើមកគណៈកម្មការសរុប រដ្ឋបាល បញ្ជូនសារ ដើម្បីបូកសរុបរាយការណ៍ជូនក្រុមប្រចាំការ និងគណៈបញ្ជាការយុទ្ធនាការបោះឆ្នោត ។

បណ្តាគណៈកម្មការជំនួយការ អាចចាត់តាំងបង្កើតជាអនុគណៈកម្មការ ឬក្រុមជំនួយការតាមសំណូមពរជាក់ស្តែងនៃការងារ ។

- គ្រប់ក្រុមការងាររបស់គណៈកម្មាធិការកណ្តាលចុះជួយខេត្ត ក្រុង ត្រូវត្រួតពិនិត្យ ណែនាំតំរង់ទិសដល់គ្រប់ខេត្ត ក្រុង អោយរៀបចំចាត់តាំង និងជំរុញសកម្មភាពរបស់គណៈបញ្ជាការ និងក្រុមយុទ្ធនាការគ្រប់ថ្នាក់អោយបានទាន់ពេលវេលា ។

- ក្នុងប្រក្រតីទិននៃការអនុវត្តន៍ផែនការនេះ ត្រូវចាប់អារម្មណ៍លើចំណុចខ្ពស់ បី ÷

+ ចំណុចខ្ពស់ទី ១ : ត្រូវក្តាប់អោយជាប់កាលបរិច្ឆេទចុះឈ្មោះបោះឆ្នោត ដើម្បីដឹកនាំណែនាំអោយគ្រប់ថ្នាក់ ចាត់តាំងសមាជិកគណបក្សទៅចុះឈ្មោះបោះឆ្នោត ។

+ ចំណុចខ្ពស់ទី ២ : ពេលយុទ្ធនាការឃោសនា ត្រូវពន្យល់សមាជិកគណបក្សអោយច្បាស់ អំពីវិធីគូសលើសន្លឹកឆ្នោតអោយត្រូវចំកន្លែងជ្រើសរើសយកសញ្ញារបស់គណបក្ស ។

+ ចំណុចខ្ពស់ទី ៣ : ថ្ងៃបោះឆ្នោត ត្រូវប្រមូលផ្តុំដឹកនាំអោយសមាជិកគណបក្សទៅបោះឆ្នោត ។

ជ. គណៈអចិន្ត្រៃយ៍

ប្រធាន

ជា ស៊ីម